សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សិទ្ធិមនុស្សត្រង់ការបញ្ចេញមតិ
## ប្រៀបមកព្រះពុទ្ធសាសនា ។

www.hoksavann.org

ថ្ងៃទី២១ សីហា ២០១១



ក្នុងមាត្រាទី១៩នៃធម្មនុញ្ញសិទ្ធិមនុស្សបានចែងថា ជនគ្រប់រូបមានសិទ្ធិសេរីភាពបញ្ចេញមតិ និងសំដែងមនោសញ្ចេតនារបស់ខ្លួនដោយឥតព្រួយបារម្ភ និងសិទ្ធិស្រាវជ្រាវទទួលនិងផ្សាយពត៌មាននិងគំនិតផ្សេងៗតាមគ្រប់មធ្យោបាយជាទូទៅ ដោយគ្មានលក្ខខណ្ឌ ។ នេះជាមាត្រាបញ្ជាក់ថា មនុស្សជាតិមានសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការបញ្ចេញយោបល់តាមសំដីនិយាយនិងការសំដែងបំណងរបស់ខ្លួនដោយពុំត្រូវមានអាជ្ញាណាមួយមករារាំងឡើយ។ នេះជាច្បាប់សាកលនៃសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដើម្បីបំរើសេចក្តីសុខឲ្យសង្គមមនុស្ស ជៀសវាងការបៀតបៀនគ្នា ។

បើយកច្បាប់នេះមកពិនិត្យមើលរបបកុម្មុយនិស្តខ្មែរក្រហមនៃប្រទេសកម្ពុជា សិទ្ធិក្នុងការបញ្ចេញយោប់ និងសិទ្ធិក្នុងការសំដែងនូវបំណងរបស់បុគ្គលមួយរូបៗ ត្រូវគេបំបាត់ចោល។ បើគេបើកឲ្យនិយាយខ្លះ ក៏និយាយតាមមេសូត្រដែលគេដាក់ឲ្យនិយាយ ដូចសេកសារិកា ។ របបនេះហាក់ដូចជាដកខួរក្បាលចេញពីប្រជាជន ដោយមនុស្សម្នាក់ៗមិនចាំបាច់ប្រើគំនិតបញ្ញាអ្វី ក្រៅតែពីធ្វើតាមមជ្ឈិមបក្សដាក់ទិសប៉ុណ្ណោះ ប្រៀបដូចជាម៉ាស៊ីនដែលមានចលនាដោយសារតែគេចុចគន្លឹះឲ្យដើរ ។ ពួកគេយល់ផ្ទុយពីធម្មជាតិរបស់មនុស្ស គឺគេយល់ថា ការឲ្យសិទ្ធិដល់បុគ្គលមួយរូបៗជាឯកជន ហាក់ដូចជាឲ្យពួកសក្តិភូមិនិងមូលធនរស់នៅជានិច្ច ។ ការពិតអនុភាពនៃបុគ្គមួយរូបៗនេះហើយ ដែលមានថាមពលអាចស្រាវជ្រាវរកឃើញការពិតអ្វីមួយ ដើម្បីអភិវឌ្ឍន៍សង្គម ដែលផ្ទុយពីលទ្ធិកុម្មុយនិស្ត ដែលបំបាត់សេរីភាពបុគ្គល ហើយថាសិទ្ធិណាមួយកើតពីពួកវាឲ្យ ពុំមែនកើតពីធម្មជាតិរបស់មនុស្ស ដែលមានតាំងពីកំណើតមកទេ បើបុគ្គលពុំមានសិទ្ធិបញ្ចេញយោបល់ទៅតាមចំណេះរបស់ខ្លួន និយាយនិងធ្វើទៅតាមតែបក្សដាក់ទិស និងនាំឲ្យប្រទេសដើរថយក្រោយ ពុំអាចលូតលាស់បានឡើយ ។ របបកុម្មុយនិស្តរំលោភសិទ្ធិមនុស្សបែបនេះ បានត្រូវដួលរលំជាបន្តបន្ទាប់គ្នា នៅសេសសល់តិចតួចណាស់ ហើយកុម្មុយនិស្តដែលនៅសេសសល់បានបន្ធូរបន្ថយកន្លែងខ្លះ ដូចបើកឲ្យមានសិទ្ធិខាងជំនឿសាសនា សិទ្ធិខាងប្រកបរបរអាជីវកម្មជាដើម តែនៅរក្សាគណបក្សមានតែមួយ គឺគណបក្សកុម្មុយនិស្ត ។

ចំពោះព្រះពុទ្ធសាសនាវិញ សម័យពុទ្ធកាល ព្រះសិទ្ធត្ថពោធិសត្វមានសិទ្ធិស្វែងរកការត្រាស់ដឹង ដើម្បីចម្លងសត្វលោកចេញចាកទុក្ខ ។ ព្រះអង្គប្រើសិទ្ធិនេះ ទើបរកឃើញអរិយសច្ច៨បានត្រាស់ជាព្រះពុទ្ធ ។ ក្រោយបានត្រាស់ជាព្រះពុទ្ធ ព្រះអង្គបានប្រើសិទ្ធិសំដែងធម៌ទេសនាប្រោសសត្វ មានសិទ្ធិបញ្ចេញយោបល់ណែនាំសត្វលោក ឲ្យខំប្រឹងប្រែងរំដោះទុក្ខចេញពីការកើតចាស់ឈឺស្លាប់ ដោយគ្មានការគំរាមកំហែងបិទសិទ្ធិនេះឡើយពេលនោះ ។ បើគ្មានសិទ្ធិនេះទេ ព្រះអង្គពុំអាចត្រាស់ដឹងជាព្រះពុទ្ធឡើយ ។ ក្នុងធម៌ទេសនា ព្រះអង្គតែងពន្យល់មនុស្សឲ្យវៀរចាកអំពើអាក្រក់ពីរប្រការតាមផ្លូវកាយនិងវាចា ដែលចាត់ទុកថាជាការគោរពសិទ្ធិមនុស្ស ។ ១- អនុប្បវាទោ ប្រែថាកុំពោលតិះដៀលបុគ្គលដទៃ ។ ២- អនុប្បឃាតោ កុំបៀតបៀននិងសម្លាប់បុគ្គលដទៃ ។ អំពើនេះអាចវៀរចាកបានដោយការរក្សាសីល ។ ព្រះអង្គពន្យល់ថា មនុស្សមានតម្លៃខ្ពង់ខ្ពស់ណាស់ បើប្រៀបមកសត្វតិរច្ឆាន ។ ដែលហៅថាមនុស្ស មកអំពីមានមនុស្សធម៌ បើប្រព្រឹត្តធ្វើអំពើអាក្រក់បៀតបៀនអ្នកដទៃ ចាត់ទុកជាមនុស្សថោកទាប ។ ព្រះពុទ្ធសំដែងថា មនុស្សមានធម្មសញ្ញា គឺមានបញ្ញា បើគេបង្ហាត់បង្រៀនចំណេះចេះដឹងមានកម្រិតកាន់តែខ្ពស់ឡើង ប្រសើរជាងសត្វតិរច្ឆាន ។ ដូច្នេះមនុស្សមានសក្តានុភាពអាចចំរើនលូតលាស់ខាងចំណេះចេះដឹង ស្គាល់ហេតុផលនិងមានសីលធម៌ បើអប់រំតាមព្រះធម៌ស្របតាមឧបនិស្ស័យរបស់ខ្លួន ដោយពុំត្រូវមានអំណាចអ្វីមួយមករារាំងក្នុងសិទ្ធិលូតលាស់នេះឡើយ ។

សិទ្ធិត្រង់ការបញ្ចេញមតិរបស់អង្គការសហប្រជាជាតិ ស្របតាមឧត្តមគតិរបស់ព្រះពុទ្ធសាសនា ដែលព្រះអង្គបានសំដែងចំនួនជាង២៥០០ឆ្នាំមកហើយ គឺត្រូវគោរពមនុស្សជាតិជាកំណើតមានតម្លៃដ៏ខ្ពង់ខ្ពស់ មិនត្រឹមតែគោរពការបញ្ចេញមតិយោបល់ទេ គឺត្រូវគោរពជីវិតមនុស្សដោយពុំត្រូវបៀតបៀនដោយអំពើបែបណាមួយឡើយ ។ ត្រង់ន័យនេះ យើងរំឭកឡើងវិញនូវអំពើឃោរឃៅរបស់ពួកខ្មែរក្រហម មិនត្រឹមតែបំបាត់ការបញ្ចេញមតិទេ លើសពីនេះទៀត ពួកនេះបានបំផ្លាញជីវិតខ្មែរអស់រាប់លាននាក់ ។ អំពើឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ផ្តើមឡើងគឺដេញប្រជាជនចេញពីក្រុង ។ មានវេជ្ជបណ្ឌិតម្នាក់សុខចិត្តស្លាប់មិនព្រមចេញតាមខ្មែរក្រហមដេញ ដោយខ្លួនកំពុងវះកាត់អ្នកជម្ងឺម្នាក់ ។ បន្ទាប់មកខ្មែរក្រហមបាញ់សម្លាប់ទាំងវេជ្ជបណ្ឌិតទាំងអ្នកជម្ងឺដែលវះកាត់។អំពើឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហមមានច្រើនយ៉ាងដោយបង្អត់អាហារធ្វើការជាទម្ងន់និងចោទយកទៅសម្លាប់ ។ គួរឲ្យរន្ធត់ណាស់ ខ្មែរក្រហមបានប្រើរដ្ឋអំណាចថ្នាក់ក្រោម ជាពិសេសតុលាការដែលគេហៅថាតុលាការប្រជាជន សុទ្ធតែមនុស្សល្ងង់ ដែលពួកនេះយល់ដឹងត្រឹមតែកំទេចគឺសម្លាប់ ដោយគ្មានដឹងហេតុផលអ្វីឡើយ ។៚

* * *